-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ប្រគេននិងជូនសប្បុរសជន ចំនួន៤រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាងព្រះវិហារ សាលាឆាន់ និងសមិទ្ធផលមួយចំនួនទៀត នៅតាមវត្តនានា ទូទាំងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | រុន | រដ្ឋា | ចៅអធិការវត្តសំរោង |
| ២-ព្រះតេជគុណ | គាញ់ | សុផា | គ្រូសូត្រស្តាំ វត្តសំរោង |
| ៣-ព្រះតេជគុណ | ឌុំ | វិធូ | គ្រូសូត្រឆ្វេង វត្តសំរោង |
| ៤-លោក | មុំ | ច័ន្ទតារា | ប្រធានមន្ទីរធម្មការនិងសាសនាខេត្ត ថវិកាចំនួន ២០.០០០ ដុល្លារ |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន៤១រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាងព្រះវិហារ សាលាឆាន់ និងសមិទ្ធផលមួយចំនួនទៀត នៅតាមវត្តនានា ទូទាំងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ឈាង** | **ផល្លី** | វិន័យធរអនុគណស្រុកស្វាយអន្ទរ | |
| ២-ព្រះតេជគុណ | **ផៃ** | **សុគ័ណ្ឌ** | ធម្មធរអនុគណស្រុកស្វាយអន្ទរ | |
| ៣-ព្រះតេជគុណ | **អ៊ឹម** | **ភា** | សមុហ៍អនុគណស្រុកស្វាយអន្ទរ | |
| ៤-ព្រះតេជគុណ | **រី** | **ចំន្ទរិទ្ធី** | ចៅអធិការវត្តស្វាយបូរព្រឹក | |
| ៥-ព្រះតេជគុណ | **ឆាន់** | **ហន** | ចៅអធិការវត្តត្រាច | |
| ៦-ព្រះតេជគុណ | **ម៉ៅ** | **គុល** | ចៅអធិការវត្តអង្គរទ្រេត | |
| ៧-ព្រះតេជគុណ | **អ៊ុច** | **ទន់** | ចៅអធិការវត្តធម្មរតន៍ | |
| ៨-ព្រះតេជគុណ | **ឈឿង** | **ទល្លី** | ចៅអធិការវត្តអូរកណ្ដាល | |
| ៩-ព្រះតេជគុណ | **ច្រឹង** | **ឃាង** | ចៅអធិការវត្តព្រៃចារ | |
| ១០-ព្រះតេជគុណ | **ពៅ** | **រីម** | ចៅអធិការវត្តជោត្តនារាម | |
| ១១-ព្រះតេជគុណ | **ហែម** | **ណន** | ចៅអធិការវត្តរកា | |
| ១២-ឧបាសក | **នូ** | **ថន** | ប្រធានអាចារ្យវត្តពោធិដ្ឋាន | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១៣-ឧបាសក | **ប៊ុន** | **ហ៊ាង** | ប្រធានគណៈកម្មការវត្តពោធិដ្ឋាន | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១៤-ឧបាសក | **ទ៉ាន់** | **តោ** | សប្បុរសជននៅវត្តព្រៃល្វី | ថវិកាចំនួន ១១.០៥៥ ដុល្លារ |
| ១៥-ឧបាសក | **ឈឹម** | **អំ** | សប្បុរសជននៅវត្តព្រៃល្វី | ថវិកាចំនួន ១១.០២០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ១៦-ឧបាសក | ស្រី | អ៊ិន | ប្រធានអាចារ្យវត្តស្វាយអាត់ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១៧-ឧបាសក | គីម | ហ៊ិន | ប្រធានគណៈកម្មការវត្តស្វាយអាត់ | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ១៨-ឧបាសក | តូច | ស៊ិន | ប្រធានអាចារ្យវត្តស្វាយបូរព្រឹក | ថវិកាចំនួន ១០.៣០០ ដុល្លារ |
| ១៩-ឧបាសក | ឃុត | វ៉េត | ប្រធានគណៈកម្មការវត្តស្វាយបូរព្រឹក | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ២០-ឧបាសក | ទ្រាំ | ថៃលាង | អនុប្រធានគណៈកម្មការវត្តស្វាយបូរព្រឹក | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២១-ឧបាសក | ស្វាយ | សំ | ប្រធានអាចារ្យវត្តត្រាច | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២២-ឧបាសក | គីម | យន | ប្រធានគណៈកម្មការវត្តត្រាច | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៣-ឧបាសក | ឆាយ | អាន | ប្រធានអាចារ្យវត្តធម្មរតន៍ | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៤-ឧបាសក | ឌី | ឌុយ | ប្រធានគណៈកម្មការវត្តធម្មរតន៍ | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៥-ឧបាសក | ឃុត | ថន | ប្រធានអាចារ្យវត្តអូរកណ្តាល | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៦-ឧបាសក | អ៊ុន | ស៊ា | ប្រធានគណៈកម្មការវត្តអូរកណ្តាល | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៧-ឧបាសក | អ៊ិន | អោ | ប្រធានអាចារ្យវត្តព្រៃចារ | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៨-ឧបាសក | អ៊ុច | យ៉ាន | ប្រធានគណៈកម្មការវត្តព្រៃចារ | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ២៩-ឧបាសក | អ៊ុន | យ៉ាន | ប្រធានអាចារ្យវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣០-ឧបាសក | ទី | នៃវ៉ាង | ប្រធានគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣១-ឧបាសក | សេង | មួន | អនុប្រធានគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣២-ឧបាសក | ឈុន | ឆន | អនុប្រធានគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៣-ឧបាសក | ឆា | អឿង | ប្រធានអាចារ្យវត្តអង្គរទ្រេត | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៤-ឧបាសក | ស៊ុន | ឆន | ប្រធានគណៈកម្មការវត្តអង្គរទ្រេត | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៥-ឧបាសក | នូ | ឡេប | អនុប្រធានគណៈកម្មការវត្តអង្គរទ្រេត | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៦-ឧបាសក | ហេង | ហ៊ុន | សមាជិកគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៧-ឧបាសក | ធី | យន | សមាជិកគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៨-ឧបាសក | នៃ | ណេម | សមាជិកគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៣៩-ឧបាសក | ញឹម | សឿន | សមាជិកគណៈកម្មការវត្តជោត្តនារាម | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៤០-ឧបាសក | តួយ | សារី | ប្រធានអាចារ្យវត្តរកា | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ៤១-ឧបាសក | ទូច | គឿន | ប្រធានគណៈកម្មការវត្តរកា | ថវិកាចំនួន ១០.១០០ ដុល្លារ |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនMr.PATHER GOTO FUMIO សប្បុរសជនជនជាតិជប៉ុន ដែលបានចូលរួមជួយកសាងអគារសិក្សាចំនួន០១ខ្នង មាន០៤បន្ទប់នៅ សាលាបឋមសិក្សាអូរដំបង២ ស្ថិតនៅក្នុងឃុំអូរដំបង២ និង អគារសិក្សាចំនួន ០១ខ្នងទៀតមានចំនួន០៥បន្ទប់ នៅសាលាបឋមសិក្សាអន្លង់ល្វា ស្ថិតនៅក្នុងឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ។

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨១១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១**.-បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣ គ្រឿង ជូនសហគមន៍ចំនួន ០៣ ដែលបានចូលរួមជួយកសាងអគារសិក្សាចំនួន ០១ ខ្នង មានចំនួន០៤បន្ទប់នៅសាលាបឋមសិក្សាអូរដំបង២ ស្ថិតនៅក្នុងឃុំអូរដំបង២ និងអគារសិក្សាចំនួន ០១ខ្នងទៀតមានចំនួន០៥បន្ទប់នៅសាលាបឋមសិក្សាអន្លង់ល្វា ស្ថិតនៅក្នុងឃុំវត្តតាមិម ស្រុក សង្កែ ខេត្តបាត់ដំបង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម៖

១-សហគមន៍ Actions For Children and Communities

២-សហគមន៍ The peace Stone Foundation,Hiroshima

៣-សហគមន៍ Brigestone Chobora Fund

**មាត្រា ២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា** ជូនលោកស្រី **តូច សុភាព** នាយិកាសាលាបឋមសិក្សាផ្កាវ ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តពោធិ៍ម្ពាន ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ចំណាយថវិកាអស់ចំនួន ៣៩.០០០ ដុល្លារអាមេរិក ។

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន៦រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនាអប់រំ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តពោធិ៍ផ្ចិត ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **សន សារិន** | សប្បុរសជន | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ២-លោក | **ឈាង សាត់** | សប្បុរសជន | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៣-លោក | **នន់ សារ៉ុន** | សប្បុរសជន | ថវិកាចំនួន ១០.៤០០ ដុល្លារ |
| ៤-ឧបាសក | **នូ ថន** | សប្បុរសជន | ថវិកាចំនួន ១០.៣០០ ដុល្លារ |
| ៥-ឧបាសក | **ចាន់ យឹន** | សប្បុរសជន | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ៦-ឧបាសក | **ម៉ុន ម៉ាច** | សប្បុរសជន | ថវិកាចំនួន ១០.១៥០ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៦ស

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥១៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ** ប្រគេន និងជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ រោងបាយ រោងម៉ាស៊ីនភ្លើង បន្ទប់ទឹក ចាក់ដីបំពេញទីធ្លាវត្ត និងចាក់បេតុងផ្លូវចូលវត្ត ស្ថិតនៅក្នុងវត្តឈើនៀងផ្អែម ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ កន្លងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ព្រះតេជគុណ | **សែស សុខន** | ចៅអធិការវត្តឈើនៀងផ្អែម | បច្ច័យ ៣៧.០០០ ដុល្លារ |
| ២- | ឧកញ៉ា | **ម៉ៅ ញ៉ន** | សប្បុរសជននៅស្រុកកោះអណ្តែត | ថវិកា ៣៧.២០០ ដុល្លារ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦១៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ២១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ រោងបាយ រោងម៉ាស៊ីនភ្លើង បន្ទប់ទឹក ចាក់ដីបំពេញទីធ្លាវត្ត និងចាក់បេតុងផ្លូវចូលវត្ត ស្ថិតនៅក្នុងវត្តឈើនៀងផ្អែម ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១- | លោក | **ម៉ាក ឆន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកា ១៥.៥០០ ដុល្លារ |
| ២- | ឧបាសិកា | **រស់ មុត** | សប្បុរសជនរស់នៅប្រទេសញ៉ូវហ្សេឡែន | ថវិកា ១៥.៤០០ ដុល្លារ |
| ៣- | លោកអាចារ្យ | **ជា ឌល** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ១០.៣០០ ដុល្លារ |
| ៤- | លោកអាចារ្យ | **រ័ត្ន ចិន** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ១០.០០០ ដុល្លារ |
| ៥- | លោកអាចារ្យ | **ខាត់ អុន** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១- | ឧបាសក | **តឿ ខុប** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ៤.៥០០ ដុល្លារ |
| ២- | ឧបាសិកា | **ទ៊ែត ណៃ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ៣.៥០០ ដុល្លារ |
| ៣- | គណៈកម្មការ | **ឡុង ព្រឿង** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ៣.២០០ ដុល្លារ |
| ៤- | គណៈកម្មការ | **ម៉ុក សោម** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ៣.១០០ ដុល្លារ |
| ៥- | គណៈកម្មការ | **គីម សឿន** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ៣.៤០០ ដុល្លារ |
| ៦- | គណៈកម្មការ | **ម៉ែន សោ** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ៣.០៥០ ដុល្លារ |
| ៧- | គណៈកម្មការ | **ឆាយ គា** | សប្បុរសជននៅឈើនៀងផ្អែម | ថវិកា ៣.០៥០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៨- | គណៈកម្មការ | ម៉ាក ផុន | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.៥០០ ដុល្លារ |
| ៩- | គណៈកម្មការ | មាញ់ ឈិន | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.១០០ ដុល្លារ |
| ១០- | គណៈកម្មការ | ណែម គុណា | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.០៥០ ដុល្លារ |
| ១១- | គណៈកម្មការ | នាក់ ផាន | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.០៥០ ដុល្លារ |
| ១២- | គណៈកម្មការ | តឿ ជីម | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.៤០០ ដុល្លារ |
| ១៣- | គណៈកម្មការ | ហ៊ុល ហ៊ិន | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.២០០ ដុល្លារ |
| ១៤- | គណៈកម្មការ | ឌីខ ហ៊ុំ | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.២០០ ដុល្លារ |
| ១៥- | គណៈកម្មការ | ឆៀង ខេង | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.១០០ ដុល្លារ |
| ១៦- | គណៈកម្មការ | គុប សារេត | សប្បុរសជននៅឈើនៀងផ្លែម | ថវិកា ៣.១០០ ដុល្លារ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តតាកែវ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ ៖** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ **មួង សុភា** អត្តលេខ ០០៤៣២៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ទោ **មាស សុវណ្ណា** អត្តលេខ ០០៤៣៣០ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

**មាត្រា២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨១៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

### សម្រេច

**មាត្រា១.**-បំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនជំនាញការជនជាតិជប៉ុន ចំនួន៨រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយរៀបចំប្រព័ន្ធទុយោទឹកស្អាតជូនប្រជាពលរដ្ឋ នៅក្រុងកំពង់ចាម ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | លោក អាដាឈី អ៊ិតស៊ឺ | ( ADACHI Itsu ) | chief Representative, JICA Cambodia Office |
| ២- | លោក អ៊ូឈីដា តូហ្គូ | ( UCHIDA Togo ) | Project Formulation Advisor, JICA Cambodia Office |
| ៣- | លោក អ៊ិស៊ីមី តាដាយូគី | ( ISHIMI Tadayuki ) | President, Representative Director |
| ៤- | លោក តូគីស៊ុ យូស៊ីហ៊ីដិ | ( TOKITSU Yoshihide ) | Director, General Manager of Tokyo Branch |
| ៥- | លោក យូកូយាមា ណូប៊ូយូគី | ( YOKOYAMA Nobuyuki ) | General Manager of Overseas Division |
| ៦- | លោក សាតូ កាហ្ស៊ុហ៊ីតូ | ( SATO Kazuhito ) | Representative of Phnom Phenh Office |

**ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១- | លោក តាកាហាស៊ី ម៉ាកូតុ | ( TAKAHASHI Makoto ) | Project Manager in Kampong Cham |
| ២- | លោក ស៊ូហ្ស៊ុគី យូស៊ីនូប៊ុ | ( SUZUKI Yoshinobu ) | Chief Engineer in Kampong Cham |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៧២០...សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩[illegible] ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត **គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍** ដែលសរសេរជាអក្សរកាត់ថា **គ.អ.ទ.** ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោមះ

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **ទី តាឃី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ូ តិរិទ្ធ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៦- ឯកឧត្តម **យុទ្ធ ភូថង** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- ឯកឧត្តម **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨- ឯកឧត្តម **ហុឺ ធីរៈ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៩- ឯកឧត្តម **សៅរី ជំនះ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- ឯកឧត្តម **គឹម សុភ័ណ** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១- ឯកឧត្តម **ជា ឧទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១២- លោកជំទាវ **ចាន់ សុម៉ាលី** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន | សមាជិក |
| ១៣- ឯកឧត្តម **ឆាយ ឫទ្ធីសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- លោកជំទាវ **តៅ សុខម៉ារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន សំបូរ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦- ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្តទាំង២៥ | | សមាជិក |
| ១៧- លោក **សុខ សុគុណា** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ ក្រសួងទេសចរណ៍ | សមាជិកអចិន្ត្រៃយ៍និងជាលេខាធិការ |

**គ.អ.ទ.** អាចមានសមាសភាពបន្ថែមមកពីក្រសួង ស្ថាប័នពាក់ពន្ធ័ផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។/

**ប្រការ២ .-**

**គ.អ.ទ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ ពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០ ប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ទេសចរណ៍ ការអនុវត្តច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ ព្រមទាំងផ្នែកដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- រៀបចំរបាយការណ៍ បូកសរុបការងារអនុវត្ត ស្ថានភាពទេសចរណ៍ លើកយោបល់ ឬដំណោះស្រាយ ព្រមទាំងវិធានការនានាជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច
- ពិនិត្យ អនុម័ត និងគ្រប់គ្រងគម្រោងផែនការសកម្មភាពរបស់ **គ.អ.ទ.**។

**ប្រការ៣ .-**

ប្រធាន **គ.អ.ទ.** ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ដំណាច់ឆមាសនីមួយៗ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធាន ១(មួយ)រូប ដែលបានទទួលសិទ្ធិពីប្រធានដឹកនាំការប្រជុំរបស់ **គ.អ.ទ.**។

ប្រធាន **គ.អ.ទ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង **គ.អ.ទ.**។

**ប្រការ៤ .-**

**គ.អ.ទ.** មានលេខាធិការដ្ឋានមួយជាជំនួយការ នៅទីស្តីការក្រសួងទេសចរណ៍។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ទ.**។

**ប្រការ៥ .-**

**គ.អ.ទ.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៦ .-**

ការចំណាយសម្រាប់កិច្ចដំណើរការ **គ.អ.ទ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិការបស់ក្រសួងទេសចរណ៍។

**គ.អ.ឆ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាននិងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.៦៤៨........សហវ

**ប្រកាស**
**ស្តីពី**
**ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម**
**របស់អគ្គនាយកដ្ឋានពន្ធដារ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈ រដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពិការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ២៨៥ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គនាយកដ្ឋានពន្ធដារ
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | ប្រធាន |
| ២. លោក **ហ៊ីម ប៊ុនធឿន** | ប្រធាននាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. លោក **លឹម ដីលុច** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ៤. លោក **ស៊ុនលី ដីនី** | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក **អែម សំអាន** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោកស្រី **ពេជ្រ បុប្ផាលក្ខ** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២.-**

ក្រុមលទ្ធកម្មមានភារកិច្ចជាសារវ័ន្ត ដូចខាងក្រោម÷

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និង ឬផែនការលទ្ធកម្មកែតម្រូវ ដោយបញ្ចូលជាឧបសម្ព័ន្ធនៃផែនការលទ្ធកម្មរបស់អគ្គនាយកដ្ឋានពន្ធដារអនុវត្តលទ្ធកម្ម ដែលត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងអនុម័ត
- អនុវត្តកិច្ចលទ្ធកម្ម ស្របតាមផែនការលទ្ធកម្មដែលត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កំណត់បុរេលក្ខណសម្បត្តិ ចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- រៀបចំ ពិនិត្យ និងសម្រេចលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន ឬបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការ ចំពោះកិច្ចលទ្ធកម្មដែលលើសសិទ្ធិសម្រេចរបស់ខ្លួន

- រៀបចំនិងផ្សព្វផ្សាយសេចក្ដីជូនដំណឹងអំពីការដេញថ្លៃ និងលក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងការដេញថ្លៃ
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃទាំងអស់ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្ដីពីការបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យនិងវាយតម្លៃលក្ខណសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ
- រៀបចំនិងផ្ញើលិខិតជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- រៀបចំការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- រៀបចំសេចក្ដីព្រាងកិច្ចសន្យា និងចុះហត្ថលេខា ជាភាគីនៃកិច្ចសន្យា ដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តកិច្ចសន្យា
- ដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម តាមសមត្ថកិច្ចរបស់ខ្លួន
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥៧៥.....សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# គោលរបបនិងនីតិវិធីចំណាយថវិកា
# សម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ២៣៧ សហវ.ប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសអន្តរក្រសួងលេខ២៩៣កបប្រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះ បណ្តាលវិជ្ជាជីវៈ

**សម្រេច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.~**

ប្រកាសអន្តរក្រសួងនេះ មានគោលដៅកំណត់គោលរបបនិងនីតិវិធីអនុវត្តចំណាយថវិកាសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២.~**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងសម្រួលនីតិវិធីនៃការអនុវត្តចំណាយថវិកា សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាឱ្យការចំណាយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ សំដៅលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា។

**ប្រការ៣.~**

ប្រកាសអន្តរក្រសួងនេះមានវិសាលភាព គ្របដណ្តប់អនុវត្តចំពោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី ២

## គោលរបបចំណាយថវិកានិងការផ្តល់អាហារូបករណ៍

**ប្រការ៤.~**

មុខសញ្ញាចំណាយសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមមានជាអាទិ៍ សម្ភារបរិក្ខារតូចតាច ឯកសារបង្រៀន សៀវភៅមើល ការផ្សព្វផ្សាយព័ត៌មានអំពីវគ្គបណ្តុះបណ្តាល ឧបត្ថម្ភគ្រូបច្ចេកទេស អ្នកសម្របសម្រួលវគ្គ ប្រជុំ និងពិធីបើក បិទវគ្គបណ្តុះបណ្តាល ។

**ប្រការ៥.-**

មុខសញ្ញាចំណាយ សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ផ្តល់ជាកញ្ចប់គោលរបបដោយគិតជាឯកតាសម្រាប់សិស្ស និងនិស្សិតម្នាក់ៗដូចខាងក្រោម÷

- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល១សប្តាហ៍ ផ្តល់គោលរបប ចំនួន ១១៣ ០០០ រៀល/សិស្សម្នាក់
- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល០៤ខែ ផ្តល់គោលរបប ចំនួន ៤០០ ០០០រៀល/សិស្សម្នាក់
- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល០៧ខែ ផ្តល់គោលរបបចំនួន៨០០ ០០០រៀល/សិស្សម្នាក់
- ចំណាយបណ្តុះបណ្តាលសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ ៣ រយៈពេល១០ខែ ផ្តល់គោលរបបចំនួន ១ ០០០ ០០០រៀល/សិស្សម្នាក់
- ចំណាយបណ្តុះបណ្តាលសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស រយៈពេល ០២ឆ្នាំ ផ្តល់គោលរបបចំនួន ៦០០ ០០០រៀល/និស្សិតម្នាក់/មួយឆ្នាំ
- ចំណាយបណ្តុះបណ្តាល បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វកររយៈពេល(០៤ឆ្នាំ) និងគរុកោសល្យ (០១ឆ្នាំ) ផ្តល់គោលរបប ចំនួន ៧០០ ០០០រៀល/និស្សិតម្នាក់ /មួយឆ្នាំ។

**ប្រការ៦.-**

ផ្តល់ប្រាក់អាហារូបករណ៍ពិសេស ដល់សិស្សសិក្សាសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ (កម្រិត ១ កម្រិត២ និងកម្រិត៣ )លើមុខជំនាញអាទិភាពដែលជាតម្រូវការទីផ្សារការងារ។ ការកំណត់មុខជំនាញ និងចំនួនអាហារូបករណ៍ត្រូវជាកម្មវត្ថុនៃការពិភាក្សាគ្នាពេលចរចាថវិកាប្រចាំឆ្នាំនីមួយៗ។

ប្រាក់អាហារូបករណ៍ពិសេសត្រូវកំណត់ផ្តល់គោលរបបចំនួន ១៦០ ០០០រៀល/សិស្សម្នាក់/មួយខែ។

## ជំពូកទី៣

## ការគ្រោងឥណទានថវិកា និងនីតិវិធីនៃការអនុវត្តថវិកា

### ផ្នែកទី១

### ការគ្រោងឥណទានថវិកា

**ប្រការ៧.-**

ឥណទានថវិកាសម្រាប់បណ្តុះបណ្តាលត្រូវគ្រោងក្នុងជំពូក ៦២ គណនី ៦២០៣ អនុគណនី ៦២០៣៦ (ចំណាយសម្រាប់ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍)។

## ផ្នែកទី២
## ការបើកផ្តល់សាច់ប្រាក់

**ប្រការ៨.~**

អាណាប័កត្រូវស្នើសុំធានាចំណាយជាកញ្ចប់ប្រចាំឆមាស សម្រាប់ចំណាយកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ការបើកផ្តល់សាច់ប្រាក់ត្រូវអនុវត្តតាមនីតិវិធីបុរេប្រទានមួយត្រីមាសម្តង។

**ប្រការ៩.~**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបង្វែរសាច់ប្រាក់ចូលគណនីរបស់អគ្គនាយកដ្ឋានអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅរៀងរាល់ដើមត្រីមាសនីមួយៗ ទៅតាមកម្មវិធីចំណាយសាច់ប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជ្រើសរើសធនាគារដៃគូណាមួយដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បើកគណនីសម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន។

បន្ទាប់ពីទទួលបានការឯកភាពលើការជ្រើសរើសធនាគារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវណែនាំដល់គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទ ដើម្បីដំណើរការបើកគណនីរៀងៗខ្លួន និងប្រមូលឯកសារពាក់ព័ន្ធនឹងការបើកគណនីនេះ ដើម្បីបូកសរុបនិងរាយការណ៍ជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

## ផ្នែកទី៣
## ការគ្រប់គ្រងថវិកា

**ប្រការ ១០.~**

ប្រធានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធ្វើជាសេនាធិការគ្រប់គ្រង និងទទួលខុសត្រូវលើរាល់ការចំណាយថវិការបស់អង្គភាពខ្លួនឱ្យទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ ១១.~**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុគឺជាមន្ត្រីនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលត្រូវឆ្លងកាត់ការបណ្តុះបណ្តាល អំពីមូលដ្ឋាននៃការអនុវត្តថវិកា និងការកាន់បញ្ជីកាគណនេយ្យ ដើម្បីមានសមត្ថភាពក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុស្របតាមវិធាន និងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

## ផ្នែកទី ៤
## ការអនុវត្តចំណាយ និង កិច្ចបញ្ជិកាគណនេយ្យ

**ប្រការ ១២.-**

ការអនុវត្តចំណាយសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

**ប្រការ ១៣.-**

គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដើម្បីស្នើសុំទូទាត់ចំណាយថវិកាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រចាំត្រីមាសនៅរៀងរាល់ដើមខែនៃត្រីមាស បន្ទាប់ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ដោយត្រូវភ្ជាប់ឯកសារ លិខិតយុត្តិការ សក្ខីបត្រចំណាយ និងប័ណ្ណចំណាយច្បាប់ដើមត្រឹមត្រូវ និងគ្រប់គ្រាន់។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំបោះអាណត្តិនិយ័តកម្ម រួចបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការចំណាយតាមនីតិវិធីហិរញ្ញវត្ថុ និងបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីទូទាត់ជម្រះបញ្ជី។

**ប្រការ ១៤.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំបង់សាច់ប្រាក់ដែលនៅសល់ចូលគណនីទោលរបស់រតនាគារឱ្យបានមុនថ្ងៃទី២៥ខែធ្នូជារៀងរាល់ឆ្នាំ។

**ប្រការ ១៥.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពុំតម្រូវឱ្យមានកិច្ចបញ្ជិកាទ្វេភាគទេ ប៉ុន្តែត្រូវកាន់បញ្ជីតាមដាន ដូចខាងក្រោម ÷

- បញ្ជីបេឡា (ត្រូវរៀបចំប័ណ្ណចំណូល ប័ណ្ណចំណាយ រាល់ពេលមានប្រតិបត្តិការសាច់ប្រាក់កើតឡើង)។
- បញ្ជីតាមដានសម្ភារ (ត្រូវរៀបចំប័ណ្ណបញ្ចូលសម្ភារទំនិញ ប័ណ្ណបញ្ចេញសម្ភារទំនិញ រាល់ពេលមានសម្ភារទំនិញចេញចូល)។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**ប្រការ ១៦.-**

សម្រាប់ការអនុវត្តឆ្នាំ២០១៦ អាណាប័ក ត្រូវស្នើសុំបុរេប្រទានសាច់ប្រាក់លើកដំបូងសម្រាប់ទ្រទ្រង់ចំណាយប្រតិបត្តិការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេល៦ខែ ជូនគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.~**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៨.~**

ថ្នាក់ដឹកនាំ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គសវនកម្មជាតិ
- ក្រសួងទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- សាលារាជធានី ខេត្ត
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



42